ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

លេខ ០១៤

# សេចក្តីណែនាំ

## ស្តីពី

## គោលការណ៍ផ្តល់ការសម្រេចលើសំណើសុំអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទ

ក្នុងគោលបំណងធានាភាពរហ័ស និងទាន់ពេលវេលា នៅក្នុងនីតិវិធីនៃការស្នើសុំច្បាប់ឈប់សម្រាកគ្រប់ប្រភេទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់ ឯកឧត្តម-លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាល អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ស្តីពីគោលការណ៍ផ្តល់ការសម្រេចលើសំណើសុំអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទ ដូចខាងក្រោម៖

១-ផ្ទេរសិទ្ធិចុះហត្ថលេខាក្នុងនាមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើរាល់សំណើសុំច្បាប់ឈប់គ្រប់ប្រភេទរបស់មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម៖

១.១-ផ្ទេរសិទ្ធិជូន ឯកឧត្តម **អគ្គលេខាធិការ អគ្គនាយក ឬ អគ្គាធិការ** ចុះហត្ថលេខាក្នុងនាមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើរាល់សំណើសុំច្បាប់ឈប់រយៈពេលចាប់ពី ១ ថ្ងៃ ដល់ ៥ ថ្ងៃ របស់មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅក្នុងអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន ឬ អគ្គាធិការដ្ឋាន ដែលមានឋានៈត្រឹមអនុប្រធាននាយកដ្ឋានចុះ ដោយចម្លងជូននាយកដ្ឋានបុគ្គលិកនៃអគ្គលេខាធិការដ្ឋានជាព័ត៌មាន។

១.២-ផ្ទេរសិទ្ធជូន ឯកឧត្តមរដ្ឋលេខាធិការ **ហ៊ាន សាហ៊ីប** ចុះហត្ថលេខាក្នុងនាមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើរាល់សំណើសុំច្បាប់ឈប់រយៈពេលចាប់ពី ៦ ថ្ងៃ ដល់ក្រោម ៣ ខែ របស់មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានឋានៈត្រឹមអនុប្រធាននាយកដ្ឋានចុះ ដោយត្រូវឆ្លងកាត់ការផ្តល់យោបល់របស់នាយកដ្ឋានបុគ្គលិកនៃអគ្គលេខាធិការដ្ឋាន តាមនីតិវិធីច្បាប់ជាធរមាន។

២-**រដ្ឋមន្ត្រី** រក្សាសិទ្ធិក្នុងការចុះហត្ថលេខា លើរាល់សំណើសុំច្បាប់ឈប់មិនគិតរយៈពេលសម្រាប់ថ្នាក់ដឹកនាំដែលមានឋានៈចាប់ពីប្រធាននាយកដ្ឋានឡើង ដោយត្រូវឆ្លងកាត់យោបល់របស់រដ្ឋលេខាធិការទទួលបន្ទុក។ ជាមួយគ្នានេះ **រដ្ឋមន្ត្រី** ចុះហត្ថលេខាលើរាល់សំណើសុំច្បាប់រយៈពេលចាប់ពី ៣ ខែ ឡើង របស់មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានឋានៈត្រឹមអនុប្រធាននាយកដ្ឋានចុះ ដោយត្រូវឆ្លងកាត់ការផ្តល់យោបល់របស់នាយកដ្ឋានបុគ្គលិកនៃអគ្គលេខាធិការដ្ឋាន។

៣-រាល់សំណើសុំច្បាប់ឈប់របស់ថ្នាក់ដឹកនាំដែលមានឋានៈចាប់ពីប្រធាននាយកដ្ឋានឡើង ត្រូវភ្ជាប់មកជាមួយនូវលិខិតផ្ទេរសិទ្ធិ។

សូមឯកឧត្តម-លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាល អគ្គនាយក អគ្គលេខាធិការ អគ្គាធិការ អនុវត្តតាមសេចក្តីណែនាំខាងលើនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៣

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន:**

- ថ្នាក់ដឹកនាំ នៃ កសហវ.
- គ្រប់អគ្គនាយកដ្ឋាន និងគ្រប់នាយកដ្ឋាន នៃ កសហវ.
- ឯកសារ-កាលប្បវត្តិ